ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ១.៩០ ប្រ.ក

# ប្រកាស
## ស្តីពី
## ការរៀបចំគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេស

## សមាហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ ន.ស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស.រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស.រកត ០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៥ ន.ស.៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសំរេច លេខ ០៩១ សសរ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការកែសំរួល និង ផ្លាស់ប្តូរសមាសភាពនៃគណៈកម្មការ យុទ្ធនាការជំរឿនស្ថិតិជនបរទេស
- យោងតាមការងារចាំបាច់

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេស ក្រសួងមហាផ្ទៃ មានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម រដ្ឋលេខាធិការ | ឯម | សំអាន | សហប្រធាន |
| ២- ឯកឧត្តម រដ្ឋលេខាធិការ | ខាន់ | សាវឿន | សហប្រធាន |
| ៣- ឯកឧត្តម នាយឧត្តមសេនីយ៍ | ហុក | ឡុងឌី | អនុប្រធាន |
| ៤- ឯកឧត្តម អគ្គនាយករដ្ឋបាល | សក់ | សេដ្ឋា | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក | សូ | ផន | អនុប្រធាន |
| ៦- ឯកឧត្តម ឧត្តមសេនីយ៍ឯក | យូ | ស៊ុនឡុង | សមាជិក |
| ៧- ឯកឧត្តម ឧត្តមសេនីយ៍ឯក | ម៉ៅ | ច័ន្ទតារា | សមាជិក |
| ៨- ឯកឧត្តម ឧត្តមសេនីយ៍ឯក | សុខ | ផល | សមាជិក |
| ៩- ឯកឧត្តម | ប៊ុល | លឹម | សមាជិក |
| ១០-លោកឧត្តមសេនីយ៍ត្រី | តៀត | ច័ន្ទថារិទ្ធ | សមាជិក |
| ១១-លោកវរៈសេនីយ៍ឯក | ហុង | ប៊ុនហ៊ាង | សមាជិក |
| ១២-លោកវរៈសេនីយ៍ឯក | រស់ | នឹមសារុន | សមាជិក |
| ១៣-លោកវរៈសេនីយ៍ឯក | ព្រហ្ម | វិមល | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារៈកិច្ច :

១- ពិនិត្យ បូកសរុបលទ្ធផលអនុវត្តផែនការលេខ ០១១ ផក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០២ របស់ក្រសួងមហាផ្ទៃ ស្តីពីយុទ្ធនាការជំរឿនស្ថិតិជនបរទេស ពិចារណាផ្តើមយោបល់ ដើម្បីស្នើសុំគោលការណ៍រាជរដ្ឋាភិបាល ដោះស្រាយចំពោះជនបរទេសបែបអន្តោប្រវេសន្ត ដែលបានស្រង់ស្ថិតិ តាមរយៈផែនការនេះ ។

២- ចាត់វិធានការអនុវត្តគោលការណ៍របស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យសំរេចទទួលស្គាល់ ឬ មិនទទួលស្គាល់ ជាជនបរទេសអន្តោប្រវេសន្តនៅកម្ពុជា ។

៣- ណែនាំ ដឹកនាំ អនុវត្តសេចក្តីណែនាំលេខ ០០២ សណន ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើនការងារគ្រប់គ្រងជនបរទេស ។

៤- ណែនាំ ដឹកនាំ ការត្រួតពិនិត្យវត្តមានជនបរទេស និង ការធ្វើការរបស់ជនបរទេសស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និង ច្បាប់ការងារ ។

៥- ចាត់វិធានការដោះស្រាយចំពោះជនបរទេស ដែលលបលាក់ចូលមកកម្ពុជាដោយខុសច្បាប់ ឬរំលោភលើបទបញ្ញត្តិច្បាប់អន្តោប្រវេសន៍ អោយស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

៦- ពិនិត្យ កសាងបទដ្ឋាននានា ពាក់ព័ន្ធដល់ការអនុវត្តន៏ច្បាប់ស្តីពីអន្តោប្រវេសន៍ និង ច្បាប់ស្តីពីសញ្ជាតិ ដែលមិនទាន់បានចែង ។

**ប្រការ ៣ :** គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួងមហាផ្ទៃ មានលេខាធិការដ្ឋាន និងក្រុមអ្នកច្បាប់ជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម :

**ក-ក្រុមលេខាធិការដ្ឋាន :**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម ឧត្តមសេនីយ៍ឯក | សុខ | ផល | ប្រធាន |
| ២- លោកឧត្តមសេនីយ៍ត្រី | តៀត | ច័ន្ទថារិទ្ធ | អនុប្រធាន |

៣- លោកវរៈសេនីយ៍ឯក ហុង ប៊ុនហ៊ាង អនុប្រធាន
៤- លោកវរៈសេនីយ៍ឯក ព្រហ្ម វិមល សមាជិក
៥- លោកវរៈសេនីយ៍ឯក ពិន ពិសិដ្ឋ សមាជិក
៦-លោកវរៈសេនីយ៍ទោ ឆន វត្ថា សមាជិក

ខ-<u>ក្រុមអ្នកច្បាប់</u> :

១-ឯកឧត្តម ប៉ុល លឹម ប្រធាន
២-លោកឧត្តមសេនីយ៍ត្រី យុក សារឿន អនុប្រធាន
៣-លោកវរៈសេនីយ៍ឯក ឌិន វ៉ាន់ដេន សមាជិក
៤-លោកវរៈសេនីយ៍ឯក ជោត សំភាង សមាជិក
៥-លោកវរៈសេនីយ៍ទោ វឿម សារិន សមាជិក

**ប្រការ ៤ :** គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួងមហាផ្ទៃ មានសិទ្ធប្រើប្រាស់ត្រាក្រសួងមហាផ្ទៃ ។

**ប្រការ ៥ :** បង្កើតគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសនៅថ្នាក់ខេត្ត-ក្រុង គ្រប់ខេត្ត និង ក្រុង ដែលមានសមាសភាព ដូចខាងក្រោម :

១- ឯកឧត្តម អភិបាលខេត្ត-ក្រុង ប្រធាន
២- ឯកឧត្តម អភិបាលរងទី១ ខេត្ត-ក្រុង អនុប្រធានទី១
៣- លោកនាយស្នងការនគរបាលខេត្ត-ក្រុង អនុប្រធាន
៤- លោកនាយស្នងការរងទី ១ នគរបាលខេត្ត-ក្រុង អនុប្រធាន
៥- លោកនាយការិយាល័យកណ្តាលសន្តិសុខ សមាជិក
៦- លោកនាយការិយាល័យជនបរទេស សមាជិក
៧- លោកអភិបាលខ័ណ្ឌ-ស្រុកទាំងអស់ សមាជិក

រាល់ការចុះហត្ថលេខារបស់ប្រធាន ត្រូវមានហត្ថលេខាសង្ខេបរបស់អនុប្រធានទី១ ។

**ប្រការ ៦ :** គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសខេត្ត-ក្រុង មានភារៈកិច្ច :

១- ពិនិត្យឡើងវិញលទ្ធផលនៃការធ្វើយុទ្ធនាការជំរឿនស្ថិតិជនបរទេស តាមរបៀបការអនុវត្តផែនការលេខ ០១១ ផក រាយការណ៍ពីការវិប្រប្រួលជូនគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួង ។

២- ចាត់វិធានការអនុវត្តសេចក្តីណែនាំលេខ ០០២ សណន ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើនការងារគ្រប់គ្រងជនបរទេស ។

៣- ចាត់វិធានការ ត្រួតពិនិត្យវត្តមានជនបរទេស និង ការធ្វើការងាររបស់ជនបរទេស នៅក្នុងភូមិសាស្ត្រខេត្ត-ក្រុងទទួលខុសត្រូវរបស់ខ្លួន ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និង ច្បាប់ការងារ និងរាយការណ៍មកគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួងមហាផ្ទៃ ។

៤- អនុវត្តការងារផ្សេងៗទៀត តាមទិសដៅ និង ការណែនាំរបស់ គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួងមហាផ្ទៃ ។

**ប្រការ ៧ :** គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសខេត្ត-ក្រុង មានក្រុមលេខាធិការជាជំនួយការ ។ សមាសភាពក្រុមលេខាធិការ អាស្រ័យដោយប្រធានគណៈកម្មការជំរឿន និងគ្រប់គ្រងជនបរទេសខេត្ត-ក្រុង ជ្រើសតាំង ។

**ប្រការ ៨ :** រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ :** អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ក្រុមអ្នកច្បាប់ក្រសួងមហាផ្ទៃ ឯកឧត្តមអភិបាលខេត្ត-ក្រុង គណៈកម្មការយុទ្ធនាការជំរឿនស្ថិតិជនបរទេស ស្ថាប័នពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងអស់លោកដែលមានឈ្មោះក្នុងប្រការ ១.៣.៥.៧ និង៩ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៦ ឆ្នាំ២០០៤

**សហរដ្ឋមន្ត្រី**

**ស ខេង** ព្រះអង្គម្ចាស់ ... [illegible]

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ១.៣.៥.៧ និង ៩

  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ.